**Declassified to Public**
**12 June 2020**

លេខ: D330

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 30 / 11 / 2016
ម៉ោង (Time/Heure) : 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេនី
Suzana TOMANOVIĆ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស")នៅក្នុងសំណុំរឿង ០០៤ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

២. ចាប់តាំងពីចាប់ផ្តើមកិច្ចស៊ើបសួរសំណុំរឿង ០០៣ មក មនុស្សចំនួន ១៩១០ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ជារឿយៗ អ្នកទាំងនោះមិនបានដាក់លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬក៏លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិជាច្រើនមានព័ត៌មានខុសគ្នា ឬមិនបានពេញលេញ ឬអត់មានសុពលភាព។

៣. ក្រោយពីពិគ្រោះយោបល់ជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរួចមក នៅក្នុងដីកាសម្រេចនេះ ខ្ញុំចាត់តាំងមេធាវីឱ្យតំណាងអ្នកដាក់ពាក្យសុំដែលមិនទាន់មានមេធាវីតំណាង និងអ្នកដាក់ពាក្យសុំដែលលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិមិនមានសុពលភាព អស់សុពលភាព ខុសគ្នា ឬមិនបានពេញលេញ ហើយបញ្ជាក់សុពលភាពម្តងទៀតចំពោះមេធាវីតំណាងអ្នកដាក់ពាក្យសុំដែល លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិដែលមានសុពលភាព។ ផ្នែកទាំងនេះនឹងដាក់បញ្ចូលគ្នានៅក្នុងឧបសម្ព័ន្ធ ខ ដល់ ឆ ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

៤. ដីកាសម្រេចនេះក៏ទុកជាកំណត់ហេតុចំពោះបញ្ជីឈ្មោះបច្ចុប្បន្នភាពរបស់មេធាវី ដែលកំពុងប្រកបវិជ្ជាជីវៈនៅអង្គការមេធាវីគ្មានព្រំដែន( Défense sans frontières)[1]។

## II. ពិភាក្សា

៥. វិធានផ្ទៃក្នុង ២៣*ស្ទួនពីរ* ចែងថា "*សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាដែលសមស្របឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ប៉ុន្តែយ៉ាងយូរបំផុតត្រឹមពេលចេញដីកាដំណោះស្រាយ*" ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានប្រយោជន៍ពីការតំណាងជាមេធាវី[2]។

---

[1]ឧបសម្ព័ន្ធ ក *អ៊ីមែលឆ្លើយឆ្លងរវាង ក.ស.ច.ស ជាមួយនឹងអង្គការមេធាវីគ្មានព្រំដែន* ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

[2]អ.វ.ត.ក វិធានផ្ទៃក្នុង ២៣*ស្ទួនពីរ* (១)។

៦. បន្ថែមពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណី អាចមានមេធាវីតំណាងរួមគ្នា ហើយ ស.ច.ស អាចរៀបចំឱ្យមានមេធាវីតំណាងរួមគ្នា តាមរយៈការចាត់តាំងដើមបណ្តឹងរដ្ឋប្បវេណី ទៅក្រុម ដែលមានស្រាប់ ឬមេធាវីដែលបានចាត់តាំងសម្រាប់តំណាងក្រុមនោះ ដោយពិគ្រោះយោបល់ជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ខណៈដែលត្រូវធានាថា *"ក្រុមផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗត្រូវបានគោរព និងទំនាស់ផលប្រយោជន៍ដទៃទៀត ក៏ត្រូវបានចៀសវាង"*[3]។

៧. សេចក្តីណែនាំអនុវត្តសម្រាប់ការចូលរួមរបស់ជនរងគ្រោះ ចែងថែមទៀតថា *"ក្នុងករណីចាំបាច់ ចៅក្រមអាចតម្រូវឱ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការជ្រើសរើសមេធាវីតំណាងរួម ឬជ្រើសតាំងមេធាវីតំណាងនោះដោយខ្លួនឯង"*[4]។

៨. អ្នកដាក់ពាក្យសុំដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ អាចស្នើសុំឱ្យពិចារណាឡើងវិញលើការចាត់តាំងមេធាវី ប្រសិនបើសំណើសមហេតុផល។

**៩. តាមសំអាងហេតុខាងលើ ខ្ញុំ៖**

១០. **បង្គាប់**ចាត់តាំងមេធាវី ឱ្យតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ខ ដល់ ឆ ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

[3]អ.វ.ត.ក វិធានផ្ទៃក្នុង ២៣*ស្ទួនពីរ* (៣)។

[4]អ.វ.ត.ក សេចក្តីណែនាំអនុវត្តសម្រាប់ការចូលរួមរបស់ជនរងគ្រោះ ០២/២០០៧/វ០១ មាត្រា ៤.៤។